# វិទ្យាស្ថានជាតិអប់រំ

National Institute of Education

## ប្រធានបទ

# កម្មវិធីប្រឹក្សាគរុកោសល្យនៅស្ថាប័នបណ្តុះបណ្តាលគ្រូបង្រៀននៅកម្ពុជា៖ តម្រូវការចាំបាច់ និងកាលានុវត្តភាព

# Mentoring Program at Teacher Training Institutions in Cambodia: Needs and Opportunities

ក្រុមស្រាវជ្រាវ៖ លោក ម៉ូត ណារិន
លោកស្រី ទៀប ច័ន្ទវត្តី
កញ្ញា លឿង កុសល

# មាតិកា

១. សេចក្តីផ្តើម

២. រំលឹកទ្រឹស្តី

៣. វិធីសាស្ត្រស្រាវជ្រាវ

៤. លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

៥. សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ១.១. សារតានៃការស្រាវជ្រាវ

- ការអភិវឌ្ឍគុណភាពគ្រូបង្រៀន គឺជាបេះដូងនៃកំណែទម្រង់ប្រព័ន្ធអប់រំនៅទូទាំងសកលលោក ជាពិសេសនៅក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍ (Darling-Hammond, 2017)
- ប្រព័ន្ធអប់រំរបស់កម្ពុជាបានឆ្លងកាត់ការកែទម្រង់សំខាន់ៗជាច្រើន ប៉ុន្តែបញ្ហាប្រឈមសំខាន់ៗនៅតែមានដូចជា កង្វះគ្រូបង្រៀន ការរៀបចំគ្រូបង្រៀនមិនគ្រប់គ្រាន់ (inadequate teacher preparation) និងឱកាសអភិវឌ្ឍន៍វិជ្ជាជីវៈគ្រូបង្រៀននៅមានកម្រិត (UNESCO, 2021)។
- ក្រសួងអប់រំ យុវជន និងកីឡា បាននិងកំពុងជម្រុញយ៉ាងសកម្មនូវ «គោលនយោបាយស្ដីពីគ្រូបង្រៀន» ដើម្បីប្រែក្លាយស្ថាប័នបណ្ដុះបណ្ដាលគ្រូ ឱ្យទៅជាមជ្ឈមណ្ឌលឆ្នើម (MoEYS, 2015)។

# ១.១. សាវតានៃការស្រាវជ្រាវ

- ការផ្លាស់ប្តូរពីបរិយាកាសសិក្សាទ្រឹស្តីទៅកាន់ការអនុវត្តជាក់ស្តែងនៅក្នុងថ្នាក់រៀន គឺជាដំណាក់កាលដ៏លំបាកបំផុតសម្រាប់គ្រូបង្រៀនថ្មីៗ (Veenman,1984)។
- កម្មវិធីប្រឹក្សាគរុកោសល្យ ត្រូវបានទទួលស្គាល់ជាអន្តរជាតិថាជាឧបករណ៍ដ៏មានប្រសិទ្ធភាពក្នុងការជួយជ្រោមជ្រែងគរុសិស្ស ឬគ្រូបង្រៀនថ្មីៗ ឱ្យមានភាពរឹងមាំទាំងផ្នែកសមត្ថភាពបង្រៀន និងផ្នែកស្មារតី (Ingersoll & Strong, 2011; Hudson, 2013)។
- ការរៀបចំឱ្យមានប្រព័ន្ធប្រឹក្សាគរុកោសល្យមួយដែលច្បាស់លាស់ មិនត្រឹមតែជួយឱ្យគរុសិស្សអាចអនុវត្តវិធីសាស្ត្របង្រៀនទំនើបៗបានជោគជ័យប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយពង្រឹងជំនាញវិជ្ជាជីវៈរបស់ពួកគេស្របតាមតម្រូវការជាក់ស្តែងនៅតាមសាលារៀនចំណេះទូទៅផងដែរ (Pich, 2017; Chea, 2024)។

# ១.២. បញ្ហានៃការស្រាវជ្រាវ

- កម្មវិធីប្រឹក្សាគរុកោសល្យ (Mentoring) មិនត្រឹមតែជាការផ្ទេរបទពិសោធន៍ប៉ុណ្ណោះទេ តែវាជាការបន្តអភិវឌ្ឍវិជ្ជាជីវៈ (Continuous Professional Development - CPD)។
- កម្មវិធីប្រឹក្សាគរុកោសល្យ ដែលមានរចនាសម្ព័ន្ធល្អអាចបង្កើនប្រសិទ្ធភាពបង្រៀនៈ តាមរយៈការសង្កេតនិងការផ្តល់មតិកែលម្អពីគ្រូប្រឹក្សាដែលមានជំនាញ (Hobson et al., 2009) បង្កើនការប្តេជ្ញាចិត្តរបស់គ្រូថ្មីចំពោះវិជ្ជាជីវៈរបស់ពួកគេ (Ingersoll & Strong, 2011)។
- កម្មវិធីប្រឹក្សាគរុកោសល្យ ត្រូវបានទទួលស្គាល់ថាជាយន្តការដ៏មានសារៈសំខាន់មួយ ដើម្បីគាំទ្រដល់គ្រូបង្រៀនថ្មី សម្រួលដល់ការអភិវឌ្ឍវិជ្ជាជីវៈរបស់ពួកគេ និងលើកកម្ពស់ការរក្សាទុកគ្រូនៅក្នុងអាជីពវិជ្ជាជីវៈ (Feiman-Nemser, 2012)។
- NIEI បានដាក់បញ្ចូលកម្មវិធីប្រឹក្សាគរុកោលស្យជាផ្នែកមួយនៃកម្មវិធីបណ្តុះបណ្តាលគ្រូរបស់ខ្លួន។ គ្រូបង្រៀនចេញថ្មី ត្រូវបានតភ្ជាប់ជាមួយអ្នកប្រឹក្សាគរុកោស្យដែលមានបទពិសោធន៍នៅតាមសាលារៀន (Tan & Caleon, 2016)។

# ១.២. បញ្ហានៃការស្រាវជ្រាវ

- ក្រសួងអប់រំ បានដាក់ចេញនូវ កម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដែលរួមបញ្ចូលទាំងការប្រឹក្សាគរុកោសល្យសម្រាប់គ្រូថ្មី។
- គ្រប់កម្មវិធីបណ្តុះបណ្តាលមុនចូលបង្រៀនទាំងអស់សុទ្ធតែមិនទាន់មានកម្មវិធីប្រឹក្សាគរុកោសល្យជាផ្លូវការក៏ដោយ ប៉ុន្តែសាកលវិទ្យាល័យល្បីៗមួយចំនួនបានបញ្ចូលវាជាយន្តការគាំទ្រ (De Vera & Del Rosario, 2018)។
- កង្វះការគាំទ្រនាំឱ្យមានផលជះអវិជ្ជមានជាច្រើននឹងកើតមានឡើងដូចជា បាត់បង់ការផ្តោតអារម្មណ៍ក្នុងការងារ បាត់បង់ទំនុកចិត្តក្នុងវិជ្ជាជីវៈជាគ្រូបង្រៀន ដែលធ្វើឱ្យប៉ះពាល់ដល់ភាពជាអ្នកអប់រំ (Qazi, Khalid, & Thomas, 2012) មានសម្ពាធ និងឈានទៅដល់ការបោះបង់អាជីពជាគ្រូបង្រៀន (Räsänen, Pietarinen, Pyhältö, Soini, & Väisänen, 2020) រាំងស្ទះដល់ការអភិវឌ្ឍវិជ្ជាជីវៈ (Ünver, 2014) ។

# ១.២. បញ្ហានៃការស្រាវជ្រាវ

- ការកំណត់អត្តសញ្ញាណនូវតម្រូវការជាក់ស្តែងរបស់គ្រូបង្រៀន និងគរុនិស្សិតនៅតាមស្ថាប័នបណ្តុះបណ្តាលគ្រូបង្រៀនទាក់ទងនឹងកម្មវិធីប្រឹក្សាគរុកោសល្យនៅមិនទាន់មានការសិក្សាគ្រប់គ្រាន់។
- តើគ្រូបង្រៀន និងគរុសិស្សមានការយល់ដឹងកម្រិតណាអំពី កម្មវិធីប្រឹក្សាគរុកោសល្យ ? តើពួកគេត្រូវការការគាំទ្រប្រភេទណាខ្លះពីគ្រូប្រឹក្សាគរុកោសល្យ? (Johnson& Johnson, 2019)។
- ការអនុវត្តកម្មវិធីប្រឹក្សាគរុកោសល្យ ត្រូវបានអនុវត្តនៅក្នុងសាលារៀនជំនាន់ថ្មី និងសាលារៀនបឋមសិក្សាមួយចំនួនដែលជាខេត្តគោលដៅ ដូចជាខេត្តកំពង់ធំ កំពត កែប កំពង់ឆ្នាំង ក្រចេះ កំពង់ស្ពឺ ស្ទឹងត្រែងព្រះវិហារឧត្តរមានជ័យ មានការសហការជួយឧបត្ថម្ភពីអង្គការក្រៅរដ្ឋាភិបាល ជាមួយនឹងក្រសួងអប់រំ យុវជន និងកីឡា មានឈ្មោះថា ការប្រឹក្សាគរុកោសល្យថ្នាក់ដំបូង។

# ១.២. បញ្ហានៃការស្រាវជ្រាវ

- ក្រសួងអប់រំ យុវជន និងកីឡាបានសហការជាមួយអង្គការVVOB ក្នុងគម្រោងSMILE បានផ្តល់ការបំប៉នកម្មវិធីប្រឹក្សាគរុកោសល្យដល់គ្រូឧទ្ទេសនៃសាលាវិក្រឹតការ និងគរុកោសល្យខេត្តទូទាំងប្រទេសកម្ពុជាផងដែរ។
- នៅវិទ្យាស្ថានជាតិអប់រំ បានបញ្ចូលមុខវិជ្ជាប្រឹក្សាគរុកោសល្យទៅក្នុងកម្មវិធីបណ្តុះបណ្តាល។
- ការបណ្តុះបណ្តាលដំបូង ការអនុវត្តជាប្រព័ន្ធនៃកម្មវិធីប្រឹក្សាគរុកោសល្យនៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន នៅតែមិនទាន់បានស្រាវជ្រាវទូលំទូលាយនៅឡើយ។
- ការស្វែងយល់ពីតម្រូវការចាំបាច់ និងឱកាសសម្រាប់ការអនុវត្តកម្មវិធីប្រឹក្សាគរុកោសល្យប្រកបដោយប្រសិទ្ធភាព គឺជាកត្តាសំខាន់សម្រាប់ការលើកកម្ពស់គុណភាពគ្រូបង្រៀន និងរួមចំណែកដល់ការកែលម្អ និងលើកកម្ពស់គុណភាពអប់រំនៅកម្ពុជា។

# ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងចម្បងនៃការស្រាវជ្រាវនេះគឺ៖

កំណត់ពីតម្រូវការរបស់គរុសិស្ស ទាក់ទងនឹងកម្មវិធីប្រឹក្សាគរុកោសល្យនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន នៅក្នុងប្រទេសកម្ពុជា។



ស្វែងរកឱកាសសម្រាប់អនុវត្តកម្មវិធីប្រឹក្សាគរុកោសល្យប្រកបដោយប្រសិទ្ធភាពនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀននៅក្នុងប្រទេសកម្ពុជា។

# ២. រំលឹកទ្រឹស្តី

| វិធីសាស្ត្របង្រៀន | ការគ្រប់គ្រងថ្នាក់រៀន | សម្ភារឧបទេស | ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ |
|---|---|---|---|
| Shulman (1987); Hudson (2013) ការជួយគរុសិស្ស បំប្លែងចំណេះដឹងទ្រឹស្តី ទៅជាការអនុវត្តវិធីសាស្ត្របង្រៀនបែបសកម្ម (Active Learning) ក្នុងថ្នាក់រៀនជាក់ស្តែង។ | Kounin (1970); Wong & Wong (2018) ការណែនាំបច្ចេកទេសគ្រប់គ្រងសណ្តាប់ធ្នាប់ វិន័យវិជ្ជមាន និងការដោះស្រាយបញ្ហាអាកប្បកិរិយារបស់សិស្សក្នុងថ្នាក់។ | Gagné (1985); Pich (2017) ការបង្វឹកគរុសិស្សឱ្យមានភាពច្នៃប្រឌិតក្នុងការផលិត និងប្រើប្រាស់សម្ភារជំនួយស្មារតីសិស្សដោយច្នៃប្រឌិតធនធានក្នុងស្រុក។ | Knowles (1980); MoEYS (2019) ការតម្រង់ទិសឱ្យគរុសិស្សយល់ដឹងពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការរៀបចំផែនការលូតលាស់ក្នុងអាជីពពេញមួយជីវិត។ |

# ២. រំលឹកទ្រឹស្ដី

| បច្ចេកវិទ្យា | ទំនាក់ទំនងក្នុងសហគមន៍ | ការគាំទ្រផ្លូវចិត្ត និងសង្គម | ការអភិវឌ្ឍជំនាញផ្ទាល់ខ្លួន និងវិជ្ជាជីវៈ |
|---|---|---|---|
| (2006) គ្រូប្រឹក្សាណែនាំគរុសិស្សក្នុងការប្រើប្រាស់កម្មវិធីអប់រំ ឧបករណ៍វាយតម្លៃឌីជីថល និងការគ្រប់គ្រងថ្នាក់រៀនដោយប្រើបច្ចេកវិទ្យា | Bronfenbrenner (1979); Epstein (2018) ការកសាងជំនាញទន់ (Soft Skills) របស់គរុសិស្សក្នុងការប្រាស្រ័យទាក់ទង និងសហការជាមួយមាតាបិតាសិស្ស និងសហគមន៍ជុំវិញសាលា។ | Black & Wiliam (2009); Chea (2024) កម្មវិធីប្រឹក្សាគរុកោសល្យដែលមានប្រសិទ្ធភាព ត្រូវតែមានតុល្យភាពរវាងការណែនាំបច្ចេកទេស និងការគាំទ្រផ្លូវចិត្ត។ | Beijaard et al. (2004) ការជម្រុញការរៀនសូត្របែបស្វ័យឆ្លុះបញ្ចាំង ដើម្បីកសាងអត្តសញ្ញាណវិជ្ជាជីវៈជាគ្រូបង្រៀន ។ |

# ២. រំលឹកទ្រឹស្តី

## ការអនុវត្តកម្មវិធីប្រឹក្សាគរុកោសល្យ

បញ្ជ្រាបកម្មវិធីប្រឹក្សាគរុកោសល្យ ទៅក្នុងកម្មវិធីសិក្សា (Low et al., 2014; NIEI, 2022)។

ប្រសិទ្ធភាពនៃការប្រើប្រាស់ PLC ដើម្បីគាំទ្រគ្រូបង្រៀនថ្មី (Ingersoll & Strong, 2011; Ronfeldt & McQueen, 2017; Darling-Hammond et al., 2017; Tan, 2013)



ផ្តល់ម៉ោងសិក្សាផ្លូវការ សម្រាប់គ្រូប្រឹក្សាចាំជួយសម្របសម្រួល (Lavonen, 2018; Niemi, 2015)។

ការបង្កើតកម្មវិធី e-Mentoring ឬ Digital Coaching (Hudson et al., 2012; Broadley & Wildy, 2012)។

# ៣. វិធីសាស្ត្រនៃការស្រាវជ្រាវ

| | |
|---|---|
| **រចនាបទស្រាវជ្រាវ** | វិធីសាស្ត្រស្រាវជ្រាវតាមបែបបរិមាណវិស័យ |
| **សំណាកគំរូ** | ២៤៨ មកពីមជ្ឈមណ្ឌលគរុកោសល្យភូមិភាគចំនួនបួន |
| **ឧបករណ៍ស្រាវជ្រាវ** | កម្រងសំណួរ ( ៣ផ្នែក ) |
| **វិធីសាស្ត្រប្រមូលទិន្នន័យ** | ការស្ទង់មតិ (Survey) |
| **វិធីសាស្ត្រវិភាគទិន្នន័យ** | មធ្យម(Mean) គម្លាត់ស្តង់ដា(SD) និង PNI Modified |

# ៣. វិធីសាស្ត្រនៃការស្រាវជ្រាវ

## វិធីសាស្ត្រវិភាគទិន្នន័យ

PNI Modified (PNI Modified Analysis Method)

- ❖ វិភាគ Current Level
- ❖ វិភាគ Expected Level

$$\textbf{PNI Modified} = \frac{EL - CL}{CL}$$

PNI > 0 → តម្រូវការខ្ពស់ ( តម្រូវការអភិវឌ្ឍ )

PNI = 0 → តម្រូវការមធ្យម

PNI < 0 → មិនមានតម្រូវការ ( ស្ថានភាពបច្ចុប្បន្នខ្ពស់ជាងស្ថានភាពរំពឹងទុក )

# ៣. វិធីសាស្ត្រនៃការស្រាវជ្រាវ

| ល.រ | សាលាគោលដៅ | ប្រជាករ | សំណាក |
|---|---|---|---|
| ១ | មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ កំពង់ចាម | ១៤៦ | ១០៦ |
| ២ | មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ព្រៃវែង | ៥២ | ៤២ |
| ៣ | មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ តាកែវ | ៣៤ | ៣៣ |
| ៤ | មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ កណ្ដាល | ៦៨ | ៦៧ |
| | សរុប | ៣០០ | ២៤៨ |

# ៤. លទ្ធផលនៃការស្រាវជ្រាវ

អ្នកចូលរួមសរុប ២៤៨នាក់ ស្រី១១៦នាក់




ក្រាបហ្វិក ១៖ ភេទ




ក្រាបហ្វិក ២៖ កម្រិតគុណវុឌ្ឍិរបស់គរុសិស្ស

# ៤. លទ្ធផលនៃការស្រាវជ្រាវ

អ្នកចូលរួមសរុប ២៤៨នាក់ ស្រី១១៦នាក់




ក្រាបហ្វិក ៣៖ ចំនួនមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ




ក្រាបហ្វិក៤៖ ឯកទេសដែលគរុសិស្សកំពុងសិក្សានៅ មជ្ឈមណ្ឌលគរុកោសល្យភូមិភាគទាំង៤

# ៤. លទ្ធផលនៃការស្រាវជ្រាវ

តារាង១៖ លទ្ធផលស្ថានភាពបច្ចុប្បន្ន និងស្ថានភាពរំពឹងទុកខេត្តកំពង់ចាម

| បរិយាយ | ស្ថានភាពបច្ចុប្បន្ន | | | ស្ថានភាពរំពឹងទុក | | | PNI | Ranking |
|---|---|---|---|---|---|---|---|---|
| | មធ្យមភាគ | គម្លាត | កម្រិត | មធ្យមភាគ | គម្លាត | កម្រិត | | |
| ក. តម្រូវការលើវិធីសាស្រ្តបង្រៀន | 2.84 | 1.19 | ល្អបង្គួរ | 4.28 | 0.57 | ខ្ពស់ណាស់ | 0.5078 | 7 |
| ខ.តម្រូវការលើការគ្រប់គ្រងថ្នាក់រៀន | 2.82 | 1.16 | ល្អបង្គួរ | 4.29 | 0.58 | ខ្ពស់ណាស់ | 0.5178 | 5 |
| គ. តម្រូវការលើការផលិតសម្ភារៈឧបទេស | 2.84 | 1.14 | ល្អបង្គួរ | 4.30 | 0.58 | ខ្ពស់ណាស់ | 0.5152 | 6 |
| ឃ.តម្រូវការលើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | 2.84 | 1.14 | ល្អបង្គួរ | 4.26 | 0.57 | ខ្ពស់ណាស់ | 0.5000 | 8 |
| ង. តម្រូវការលើបច្ចេកវិទ្យា | 2.82 | 1.18 | ល្អបង្គួរ | 4.35 | 0.60 | ខ្ពស់ណាស់ | 0.5407 | 3 |
| ច. តម្រូវការក្នុងទំនាក់ទំនងសហគមន៍ | 2.54 | 1.13 | មធ្យម | 4.11 | 0.68 | ខ្ពស់ | 0.6202 | 1 |
| ឆ.ការទទួលបានការគាំទ្រផ្លូវចិត្ត និងសង្គម | 2.70 | 1.11 | ល្អបង្គួរ | 4.25 | 0.57 | ខ្ពស់ណាស់ | 0.5713 | 2 |
| ជ. ការអភិវឌ្ឍជំនាញផ្ទាល់ខ្លួន និងវិជ្ជាជីវៈ | 2.82 | 1.15 | ល្អបង្គួរ | 4.32 | 0.54 | ខ្ពស់ណាស់ | 0.5326 | 4 |
| សរុបមធ្យមភាគ | 2.78 | 1.15 | ល្អបង្គួរ | 4.27 | 0.59 | ខ្ពស់ | 0.5382 | |

# ៤. លទ្ធផលនៃការស្រាវជ្រាវ

## តារាង២៖ លទ្ធផលស្ថានភាពបច្ចុប្បន្ន និងស្ថានភាពរំពឹងទុកខេត្តព្រៃវែង

| បរិយាយ | ស្ថានភាពបច្ចុប្បន្ន | | | ស្ថានភាពរំពឹងទុក | | | PNI | Ranking |
|---|---|---|---|---|---|---|---|---|
| | មធ្យមភាគ | គម្លាត | កម្រិត | មធ្យមភាគ | គម្លាត | កម្រិត | | |
| ក. តម្រូវការលើវិធីសាស្ត្របង្រៀន | 2.13 | 0.46 | មធ្យម | 4.06 | 0.44 | ខ្ពស់ | 0.8996 | 8 |
| ខ.តម្រូវការលើការគ្រប់គ្រងថ្នាក់រៀន | 2.10 | 0.47 | មធ្យម | 4.08 | 0.49 | ខ្ពស់ | 0.9452 | 5 |
| គ. តម្រូវការលើការផលិតសម្ភារៈឧបទេស | 2.08 | 0.49 | មធ្យម | 4.06 | 0.48 | ខ្ពស់ | 0.9505 | 6 |
| ឃ.តម្រូវការលើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | 2.05 | 0.44 | មធ្យម | 4.08 | 0.48 | ខ្ពស់ | 0.9922 | 4 |
| ង. តម្រូវការលើបច្ចេកវិទ្យា | 2.04 | 0.48 | មធ្យម | 4.10 | 0.47 | ខ្ពស់ | 1.0156 | 3 |
| ច. តម្រូវការក្នុងទំនាក់ទំនងសហគមន៍ | 1.76 | 0.51 | ខ្សោយ | 3.92 | 0.58 | ខ្ពស់ | 1.2230 | 1 |
| ឆ.ការទទួលបានការគាំទ្រផ្លូវចិត្ត និងសង្គម | 1.92 | 0.47 | មធ្យម | 4.05 | 0.49 | ខ្ពស់ | 1.1118 | 2 |
| ជ. ការអភិវឌ្ឍជំនាញផ្ទាល់ខ្លួន និងវិជ្ជាជីវៈ | 2.10 | 0.48 | មធ្យម | 4.03 | 0.43 | ខ្ពស់ | 0.9223 | 7 |
| សរុបមធ្យមភាគ | 2.02 | 0.48 | មធ្យម | 4.05 | 0.48 | ខ្ពស់ | 1.0075 | |

# ៤. លទ្ធផលនៃការស្រាវជ្រាវ

## តារាង៣៖ លទ្ធផលស្ថានភាពបច្ចុប្បន្ន និងស្ថានភាពរំពឹងទុកខេត្តតាកែវ

| បរិយាយ | ស្ថានភាពបច្ចុប្បន្ន | | | ស្ថានភាពរំពឹងទុក | | | PNI | Ranking |
|---|---|---|---|---|---|---|---|---|
| | មធ្យមភាគ | គម្លាត | កម្រិត | មធ្យមភាគ | គម្លាត | កម្រិត | | |
| ក. តម្រូវការលើវិធីសាស្ត្របង្រៀន | 2.42 | 0.94 | មធ្យម | 3.74 | 0.64 | ខ្ពស់ | 0.5449 | 8 |
| ខ.តម្រូវការលើការគ្រប់គ្រងថ្នាក់រៀន | 2.48 | 0.93 | មធ្យម | 4.10 | 0.70 | ខ្ពស់ | 0.6517 | 5 |
| គ. តម្រូវការលើការផលិតសម្ភារៈឧបទេស | 2.48 | 0.95 | មធ្យម | 4.06 | 0.79 | ខ្ពស់ | 0.6321 | 6 |
| ឃ.តម្រូវការលើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | 2.35 | 0.98 | មធ្យម | 4.24 | 0.66 | ខ្ពស់ណាស់ | 0.8065 | 1 |
| ង. តម្រូវការលើបច្ចេកវិទ្យា | 2.42 | 0.94 | មធ្យម | 4.14 | 0.80 | ខ្ពស់ | 0.7083 | 3 |
| ច. តម្រូវការក្នុងទំនាក់ទំនងសហគមន៍ | 2.52 | 0.88 | មធ្យម | 3.90 | 0.82 | ខ្ពស់ | 0.5522 | 7 |
| ឆ.ការទទួលបានការគាំទ្រផ្លូវចិត្ត និងសង្គម | 2.47 | 0.93 | មធ្យម | 4.11 | 0.74 | ខ្ពស់ | 0.6626 | 4 |
| ជ. ការអភិវឌ្ឍជំនាញផ្ទាល់ខ្លួន និងវិជ្ជាជីវៈ | 2.39 | 0.96 | មធ្យម | 4.26 | 0.59 | ខ្ពស់ណាស់ | 0.7785 | 2 |
| សរុបមធ្យមភាគ | 2.44 | 0.94 | មធ្យម | 4.07 | 0.72 | ខ្ពស់ | 0.6671 | |

# ៤. លទ្ធផលនៃការស្រាវជ្រាវ

## តារាង៤៖ លទ្ធផលស្ថានភាពបច្ចុប្បន្ន និងស្ថានភាពរំពឹងទុកខេត្តកណ្ដាល

| បរិយាយ | ស្ថានភាពបច្ចុប្បន្ន | | | ស្ថានភាពរំពឹងទុក | | | PNI | Ranking |
|---|---|---|---|---|---|---|---|---|
| | មធ្យមភាគ | គម្លាត | កម្រិត | មធ្យមភាគ | គម្លាត | កម្រិត | | |
| ក. តម្រូវការលើវិធីសាស្ត្របង្រៀន | 2.05 | 1.08 | មធ្យម | 4.03 | 0.90 | ខ្ពស់ | 0.9672 | 2 |
| ខ.តម្រូវការលើការគ្រប់គ្រងថ្នាក់រៀន | 2.11 | 1.05 | មធ្យម | 3.95 | 0.95 | ខ្ពស់ | 0.8681 | 7 |
| គ. តម្រូវការលើការផលិតសម្ភារៈឧបទេស | 2.01 | 1.00 | មធ្យម | 3.97 | 1.00 | ខ្ពស់ | 0.9752 | 1 |
| ឃ.តម្រូវការលើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | 2.15 | 1.09 | មធ្យម | 3.95 | 1.02 | ខ្ពស់ | 0.8314 | 8 |
| ង. តម្រូវការលើបច្ចេកវិទ្យា | 2.14 | 1.07 | មធ្យម | 4.02 | 0.99 | ខ្ពស់ | 0.8779 | 6 |
| ច. តម្រូវការក្នុងទំនាក់ទំនងសហគមន៍ | 1.98 | 1.00 | មធ្យម | 3.77 | 1.02 | ខ្ពស់ | 0.9009 | 4 |
| ធ.ការទទួលបានការគាំទ្រផ្លូវចិត្ត និងសង្គម | 2.03 | 0.98 | មធ្យម | 3.92 | 0.94 | ខ្ពស់ | 0.9254 | 3 |
| ជ. ការអភិវឌ្ឍជំនាញផ្ទាល់ខ្លួន និងវិជ្ជាជីវៈ | 2.10 | 1.07 | មធ្យម | 3.96 | 1.03 | ខ្ពស់ | 0.8828 | 5 |
| សរុបមធ្យមភាគ | 2.02 | 0.48 | មធ្យម | 4.05 | 0.48 | ខ្ពស់ | 1.0075 | |

# ៤. លទ្ធផលនៃការស្រាវជ្រាវ

## តារាង៥៖ លទ្ធផលស្ថានភាពបច្ចុប្បន្ន និងស្ថានភាពរំពឹងទុក

| បរិយាយ | ស្ថានភាពបច្ចុប្បន្ន | | | ស្ថានភាពរំពឹងទុក | | | PNI | Ranking |
|---|---|---|---|---|---|---|---|---|
| | មធ្យមភាគ | គម្លាត | កម្រិត | មធ្យមភាគ | គម្លាត | កម្រិត | | |
| ក. តម្រូវការលើវិធីសាស្ត្របង្រៀន | 2.45 | 1.10 | មធ្យម | 4.10 | 0.76 | ខ្ពស់ | 0.6742 | 8 |
| ខ.តម្រូវការលើការគ្រប់គ្រងថ្នាក់រៀន | 2.46 | 1.07 | មធ្យម | 4.13 | 0.71 | ខ្ពស់ | 0.6786 | 7 |
| គ. តម្រូវការលើការផលិតសម្ភារៈឧបទេស | 2.44 | 1.06 | មធ្យម | 4.14 | 0.75 | ខ្ពស់ | 0.6963 | 5 |
| ឃ.តម្រូវការលើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ | 2.46 | 1.07 | មធ្យម | 4.14 | 0.73 | ខ្ពស់ | 0.6870 | 6 |
| ង. តម្រូវការលើបច្ចេកវិទ្យា | 2.45 | 1.09 | មធ្យម | 4.19 | 0.74 | ខ្ពស់ | 0.7091 | 3 |
| ច. តម្រូវការក្នុងទំនាក់ទំនងសហគមន៍ | 2.25 | 1.03 | មធ្យម | 3.96 | 0.81 | ខ្ពស់ | 0.7566 | 1 |
| ឆ.ការទទួលបានការគាំទ្រផ្លូវចិត្ត និងសង្គម | 2.36 | 1.03 | មធ្យម | 4.11 | 0.72 | ខ្ពស់ | 0.7410 | 2 |
| ជ. ការអភិវឌ្ឍជំនាញផ្ទាល់ខ្លួន និងវិជ្ជាជីវៈ | 2.45 | 1.07 | មធ្យម | 4.16 | 0.72 | ខ្ពស់ | 0.7025 | 4 |
| សរុបមធ្យមភាគ | 2.41 | 1.06 | មធ្យម | 4.12 | 0.74 | ខ្ពស់ | 0.7057 | |

# ៤. លទ្ធផលនៃការស្រាវជ្រាវ

## ផ្នែកទីIII

តារាង៦៖ ឱកាសសម្រាប់គរុសិស្សអនុវត្តកម្មវិធីប្រឹក្សាគរុកោសល្យ

| ឱកាសសម្រាប់អនុវត្តកម្មវិធីប្រឹក្សាគរុកោសល្យដល់គរុសិស្ស | មធ្យមភាគ | គម្លាត | កម្រិត |
|---|---|---|---|
| ក. បញ្ញ្រាបក្នុងកម្មវិធីសិក្សា | 4.02 | 0.70 | ខ្ពស់ |
| ខ. ការចូលរួមសហគមន៍សិក្សាវិជ្ជាជីវៈ និងការបំប៉នសមត្ថភាព | 3.96 | 0.75 | ខ្ពស់ |
| គ. ការធ្វើស្វ័យសិក្សា និងសិក្សាស្រាវជ្រាវ | 3.93 | 0.76 | ខ្ពស់ |
| ឃ. ក្នុងការទទួលបានបំណិនបុរេសកម្ម | 4.00 | 0.71 | ខ្ពស់ |
| ង.ការចូលរួមទំនាក់ទំនងសហគមន៍ | 3.88 | 0.77 | ខ្ពស់ |

# ៥. ការពិភាក្សា និងសន្និដ្ឋាន

- លទ្ធផលរកឃើញចម្បងនៃការស្រាវជ្រាវនេះ គឺការលេចឡើងនៃតម្រូវការលើទំនាក់ទំនងសហគមន៍ និងតម្រូវការគាំទ្រផ្លូវចិត្តជាអាទិភាពលំដាប់ខ្ពស់បំផុត។ សមាសភាគបច្ចេកទេសដូចជា វិធីសាស្ត្របង្រៀនបែបជាស្ថិតនៅលំដាប់ទាបទៅវិញ។ នេះបញ្ជាក់ថាស្ថាប័នបណ្តុះបណ្តាលគ្រូនៅកម្ពុជាបានធ្វើកិច្ចការយ៉ាងល្អរួចទៅហើយក្នុងការបណ្តុះបណ្តាលទ្រឹស្តីវិធីសាស្ត្របង្រៀននៅក្នុងថ្នាក់ ស្របតាមការរកឃើញរបស់ Pich (2017)។

- ការរកឃើញនេះគាំទ្រយ៉ាងរឹងមាំដល់ទ្រឹស្តីរបស់ Hudson (2013) ត្រង់កត្តាលក្ខណៈបុគ្គល ដែលសង្កត់ធ្ងន់ថា គ្រូប្រឹក្សាដែលមានប្រសិទ្ធភាព មិនមែនគ្រាន់តែជាអ្នកមកត្រួតពិនិត្យកិច្ចតែងការបង្រៀននោះទេ ប៉ុន្តែត្រូវដើរតួជាអ្នកផ្តល់ការគាំទ្រផ្នែកចិត្តសង្គម (Psychosocial Support) ដើម្បីបង្កើតបរិយាកាសសុវត្ថិភាពផ្លូវចិត្ត (Psychological Safety)។ បើគ្មានការគាំទ្រផ្លូវចិត្តនោះទេ គរុសិស្សនឹងមាននិន្នាការធ្លាក់ទឹកចិត្ត និងបោះបង់យុទ្ធសាស្ត្របង្រៀនទំនើបៗចោល (Black & Wiliam, 2009; Chea, 2024)។

# ៥. ការពិភាក្សា និងសន្និដ្ឋាន

- ចំណុចដ៏សំខាន់មួយទៀត គឺការប្រែប្រួលលំនាំតម្រូវការរវាងខេត្តតាកែវ និងខេត្តកណ្ដាល។ នៅខេត្តតាកែវ គរុសិស្សចាត់ទុកការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ( CPD) ជាអាទិភាពទី១ ( PNI = 0.8065) ដែលស្របនឹងទ្រឹស្ដី Andragogy របស់ Knowles (1980) ត្រង់ការយល់ដឹងពីអនាគតអាជីពរយៈពេលវែង។
- ផ្ទុយទៅវិញ នៅខេត្តកណ្ដាល គរុសិស្សផ្ដោតខ្លាំងលើការផលិតសម្ភារឧបទេស ( PNI = 0.9752) និងវិធីសាស្ត្របង្រៀន ( PNI = 0.9672) ដែលឆ្លុះបញ្ចាំងពីបញ្ហាប្រឈមចំពោះមុខក្នុងថ្នាក់រៀន ( Case-specific instructional deficit) (Gagné, 1985)។

# ៥. ការពិភាក្សា និងសន្និដ្ឋាន

- ផ្នែកកាលានុវត្តភាពបានបង្ហាញនូវប្រេកចេញរួមមួយ ដោយគរុនិស្សិតទាំងអស់បានវាយតម្លៃខ្ពស់បំផុតលើការបញ្ជ្រាបកម្មវិធីប្រឹក្សាទៅក្នុងកម្មវិធីសិក្សាផ្លូវការ (M = 4.02) និង «ការប្រើប្រាស់សហគមន៍សិក្សាវិជ្ជាជីវៈ PLC (M = 3.96)។
- នេះមានន័យថា ឱកាសនៃការបង្កើតបណ្តាញគាំទ្រឌីជីថល (Digital Coaching) តាមរយៈតេឡេក្រាម និងការជួបជុំបែប PLC គឺជាកាតាលីករដ៏មានលទ្ធភាពខ្ពស់ក្នុងការឆ្លើយតបទៅនឹងគម្លាតខ្វះខាតទាំងឡាយដែលបានរកឃើញ (Banh,n.d.; MoEYS, 2019)។

# សន្និដ្ឋាន

- កម្រិតតម្រូវការចាំបាច់របស់គរុសិស្ស មានការផ្លាស់ប្តូរទម្រង់ពីតម្រូវការបច្ចេកទេសគរុកោសល្យទៅរកតម្រូវការលើជំនាញទន់ក្នុងទំនាក់ទំនងសហគមន៍ និងការគាំទ្រផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ។
- ឱកាសក្នុងការដោះស្រាយបញ្ហានេះ គឺស្ថិតនៅលើការរៀបចំកម្មវិធីប្រឹក្សាគរុកោសល្យទៅក្នុងកម្មវិធីសិក្សាផ្លូវការរបស់ស្ថាប័នបណ្តុះបណ្តាលគ្រូបង្រៀន និងការចាប់យកយន្តការសហគមន៍សិក្សាវិជ្ជាជីវៈ (PLC) រួមផ្សំនឹងបច្ចេកវិទ្យាឌីជីថល។
- ការអនុវត្តកម្មវិធីប្រឹក្សាគរុកោសល្យនៅកម្ពុជានាពេលបច្ចុប្បន្ន មានគម្លាតខ្ពស់ (PNI total = 0.7057) ដែលទាមទារឱ្យមានការរៀបចំឡើងវិញជាបន្ទាន់នូវក្របខណ្ឌគាំទ្រដើម្បីកសាងសមត្ថភាពគ្រូបង្រៀនជំនាន់ថ្មីប្រកបដោយគុណភាព និងចីរភាព។

# សំណូមពរ

## ចំពោះក្រសួងអប់រំ យុវជន និងកីឡា

- បន្តជម្រុញ និងគាំទ្រដល់កម្មវិធីប្រឹក្សាគរុកោសល្យ




## ចំពោះគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ 02

- សិក្សាពីតម្រូវការចាំបាច់នៅតាមគ្រឹះស្ថាន និងបញ្ចូលកម្មវិធីប្រឹក្សាគរុកោសល្យទៅក្នុងកម្មវិធីសិក្សាផ្លូវការ។

## ចំពោះការស្រាវជ្រាវនាពេលអនាគត

- ដោយសារការសិក្សានេះប្រើប្រាស់វិធីសាស្ត្របរិមាណវិស័យតែមួយមុខ ការស្រាវជ្រាវបន្ទាប់គួរតែប្រើប្រាស់ វិធីសាស្ត្រចម្រុះ (Mixed-Methods Design) ដោយបន្ថែមការសម្ភាសស៊ីជម្រៅ (In-depth Interviews) ជាមួយគ្រូប្រឹក្សា និងគណៈគ្រប់គ្រងសាលា ដើម្បីទទួលបានទិន្នន័យត្រីកោណកម្ម (Triangulation) កាន់តែលម្អិត។
- គួរតែមានការសិក្សាស្រាវជ្រាវតាមដានរយៈពេលវែង (Longitudinal Study) ដើម្បីវាយតម្លៃពីផលជះនៃកម្មវិធីប្រឹក្សាគរុកោសល្យ នៅក្នុងប្រព័ន្ធអប់រំកម្ពុជា។

# សូមអរគុណ

# សម្រាប់ការយកចិត្តទុកដាក់